ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៦៤៤
ចុះថ្ងៃទី ២៦-០១-២០១៧
ជំនុំជម្រះ
លេខ ១៧០៤
ចុះថ្ងៃទី ១៩-០៥-២០១៧
សាលក្រម
លេខ ១៩០០ "ឡ"
ចុះថ្ងៃទី២៨-០៧-២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី ០៤-០៧-២០១៧ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក[redacted] ចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក[redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក[redacted] ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៦៤៤ ចុះថ្ងៃទី ២៦-០១-២០១៧ ដែលមានជនជាប់ចោទឈ្មោះ[redacted]ភេទ ប្រុស អាយុ ២៩ ឆ្នាំ ជាតិ ខ្មែរ មុខរបរ បុគ្គលិកក្រុមហ៊ុន ទីកន្លែងកំណើត ភូមិត្រពាំងវិល ឃុំត្រវិល ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃាត់ខ្លួន ផ្ទះជួល ផ្លូវលំ ក្រុមទី១០ ភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] "រស់" ម្តាយឈ្មោះ[redacted] "រស់" ប្រពន្ធឈ្មោះ[redacted] (លែងលះ) មានកូន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន ។

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៧៧៤ "ស" ជ.ឃ.ជ ចុះថ្ងៃទី ២៩-០១-២០១៧ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

ជាប់ចោទពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនសាប៊ូប៊ីជីស៊ីលីមីត ផ្លូវបេតុង ក្រុមទី១៤ ភូមិទួលថ្កាន់ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦-១២-២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ៣៩១ , ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ភេទ ស្រី អាយុ ៤៧ ឆ្នាំ ជាតិ ខ្មែរ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ២៥ ផ្លូវលេខ៤៩០ ក្រុមទី១៣ ភូមិ២ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

មានលោកមេធាវី[redacted]និងលោក[redacted]មេធាវីការពារសិទ្ធិ ។



Scanned by CamScanner

## អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ៖

កាលពីថ្ងៃទី ២៦-១២-២០១៦ ជនសង្ស័យឈ្មោះ [redacted] ជាបុគ្គលិកក្រុមហ៊ុនប៊ីឌីស៊ីលីមីត បាន យកសាប៊ូទៅបោះឲ្យម៉ូយនៅតាមទីផ្សារ ដោយគិតជាតម្លៃប្រាក់សរុបចំនួន ៣.១២៧,៧៥$ (បីពាន់មួយរយម្ភៃប្រាំពីរដុល្លារអាមេរិក ក្បៀសចិតសិបប្រាំសេន) ហើយមិនប្រគល់ប្រាក់ឲ្យក្រុមហ៊ុនទេ។ ដោយយកប្រាក់ខាងលើ យកទៅសងបំណុលរបស់ប្រពន្ធខ្លួនអស់ភ្លាមៗ ក៏ត្រូវប្រធានរដ្ឋបាលនាំប្រគល់ឲ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលទួលសង្កែ ដើម្បីធ្វើការសាកសួរតែម្តង ។

-បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី ២៤-០១-២០១៧ របស់ឈ្មោះ [redacted] ។

-បានឃើញរបាយការណ៍សំយោគលេខ ០៤៧/១៧ រ.ប.ក ចុះថ្ងៃទី ២៥-០១-២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌឬស្សីកែវ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៥០៣ អ.យ.ប ចុះថ្ងៃទី ២៨-០១-២០១៧ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១១៨១ អ.យ.ប ចុះថ្ងៃទី ២៤-០៤-២០១៧ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបង្គាប់ឱ្យរក្សាទុកជនត្រូវចោទនៅជាប់ឃុំបណ្តោះអាសន្នលេខ ៣២១៥ "ស" ដ.យ.ជ ចុះថ្ងៃទី ០២-០៥-២០១៧ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦១២ "ស" ដ.ជ ចុះថ្ងៃទី ០២-០៥-២០១៧ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

## ចំណាក់កាលសួរដេញដោល

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថាៈ ខ្លួនជាបុគ្គលិករបស់ក្រុមហ៊ុនប៊ីឌី ស៊ីលីមីត ផ្នែកចែកចាយសាប៊ូ ។ នៅថ្ងៃទី២៤-១២-២០១៦ វេលាម៉ោង ០៨:០០នាទី ខ្លួនបានយកសាប៊ូទៅបោះឲ្យម៉ូយនៅតាមផ្សារ ដោយគិតជាតម្លៃប្រាក់សរុបមានចំនួន ៣.១២៧,៧៥ $ (បីពាន់មួយរយម្ភៃ ប្រាំពីរដុល្លារអាមេរិក ក្បៀសចិតសិបប្រាំសេន) ហើយខ្លួនមិនបានប្រគល់ប្រាក់ខាងលើឲ្យក្រុមនោះទេ ដោយយកប្រាក់ទាំងអស់ទៅសងបំណុលរបស់ប្រពន្ធខ្លួនដែលជំពាក់គេ ។ លុះដល់ថ្ងៃទី២៤-០១-២០១៧ វេលាម៉ោង០៧:៣០នាទី រូបខ្លួនបានចូលមកក្រុមហ៊ុន ត្រូវបានប្រធានរដ្ឋបាលឈ្មោះ [redacted] ហៅមកទូទាត់ប្រាក់ខាងលើឲ្យក្រុមហ៊ុន ហើយរូបខ្លួនបាននិយាយទៅកាន់ប្រធានរដ្ឋបាលថាប្រាក់ចំនួន៣.១២៧,៧៥$(បីពាន់មួយរយម្ភៃប្រាំពីរដុល្លារអាមេរិក ក្បៀសចិតសិបប្រាំសេន)រូបខ្លួនបានយកទៅសងបំណុលគេអស់ហើយ ភ្លាមៗនោះក៏ត្រូវប្រធានរដ្ឋបាលធ្វើការឃាត់រូបខ្លួនប្រគល់ឲ្យប៉ុស្តិ៍នគរបាលរដ្ឋបាលទួលសង្កែតែម្តង ។

-លោកមេធាវី [redacted] ជាមេធាវីតំណាងអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថាៈ ខ្លួនរក្សាការទាមទារដូចនៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់កូនក្តីខ្លួនទុកជាបានការដដែល ។ ចំពោះរឿងដែលឈ្មោះ [redacted] បានយកប្រាក់របស់ក្រុមហ៊ុនកូនក្តីខ្លួននោះគឺបានកើតឡើងតាំងពីឆ្នាំ២០១៥ រហូតមកដល់ខែមករា ដើមឆ្នាំ២០១៧នេះ ទើបកូនក្តីខ្លួនបានដាក់ពាក្យបណ្តឹងប្តឹងឈ្មោះ [redacted] ដោយមូលហេតុឈ្មោះនេះបានយកប្រាក់របស់ក្រុមហ៊ុនកូនក្តីខ្លួនជាច្រើនដងមកហើយ ទើបតែដើមឆ្នាំ២០១៧នេះ ទើបកូនក្តីខ្លួនបានសម្រេចដាក់ពាក្យបណ្តឹងសមត្ថកិច្ច និងរហូតមកដល់តុលាការតែម្តង។ ខ្លួនសូមបញ្ជាក់ថា ប្រាក់ដែលឈ្មោះ [redacted] នយកនោះមានចំនួន ៥.០៦១,៨៥$



Scanned by CamScanner

(ប្រាំពាន់សូន្យរយហុកសិបមួយដុល្លារអាមេរិក ក្បៀសប៉ែតសិបប្រាំសេន) គិតត្រឹមថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ហើយខាងកូនក្តីខ្លួនក៏បានកំពុងតែស្រាវជ្រាវបន្ថែមទៀតអំពីចំនួនទឹកប្រាក់ដែលឈ្មោះ [redacted] បានយកថាមានចំនួនសរុបប៉ុន្មាន ដោយសារថាការប្រព្រឹត្តរបស់ឈ្មោះ [redacted] បានប្រព្រឹត្តជាយូរមកហើយ ។

សំណូមពរសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ និងប្តឹងទាមទារឱ្យឈ្មោះ [redacted] សងប្រាក់មកឱ្យក្រុមហ៊ុនកូនក្តីខ្លួនវិញគ្រប់ចំនួន ។

-តាមអំណានកំណត់ហេតុបណ្តឹង ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] នៅចំពោះមុខប៉ុស្តិ៍នគរបាលរដ្ឋបាលទួលសង្កែ បញ្ជាក់ថា: ឈ្មោះ [redacted] ភេទ ប្រុស បានចូលបំរើការងារនៅក្រុមហ៊ុន BDC រយៈពេលពីរឆ្នាំហើយ នៅផ្នែកលក់សាប៊ូ ។ ប្រធានក្រុមហ៊ុនបានប្រគល់ឱ្យឈ្មោះ [redacted] ជាអ្នកដើរយកប្រាក់នៅទីផ្សារ ។ លុះនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ វេលាម៉ោង ០៨:០០ព្រឹក ខ្លួន(ហាម សេឡា) នៅផ្នែករដ្ឋបាលបានត្រួតពិនិត្យបុងប្រាក់បាត់ប្រាក់ចំនួន៣.១២៧,៧៥$ (បីពាន់មួយរយម្ភៃប្រាំពីរដុល្លារអាមេរិក ក្បៀសចិតសិបប្រាំសេន) ដែលឈ្មោះ [redacted] ទាន់បានប្រគល់ឱ្យក្រុមហ៊ុនវិញទេ ហើយខ្លួនបានដំណើរទៅសួរគ្រប់ទីផ្សារ អាជីវករ ដែលបានទទួលយកសាប៊ូទៅលក់បន្ត ពួកគាត់បានប្រាប់ថា ប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] ជាអ្នកយកប្រាក់ជារៀងរាល់លើកអស់ហើយ ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] បានឆ្លើយនៅសមត្ថកិច្ច និងនៅចៅក្រមស៊ើបសួរ ប្រហាក់ប្រហែលគ្នាថា: នៅថ្ងៃទី២៤-០១-២០១៧ វេលាម៉ោង០៧:៣០នាទី រូបខ្លួនបានទៅកន្លែងធ្វើការក្នុងក្រុមហ៊ុនលក់សាប៊ូប៊ីឌីស៊ីលីមីត ស្រាប់តែឃើញប្រធានរដ្ឋបាលឈ្មោះ [redacted] ហៅឈ្មោះ [redacted] អ្នកលក់សាប៊ូនៅតាមទីផ្សារឲ្យមកទូទាត់ប្រាក់របស់ក្រុមហ៊ុន ក្រោយមកស្រាប់តែប្រធានរដ្ឋបាលបានហៅរូបខ្លួនឲ្យនាំឈ្មោះ [redacted] ប្រគល់ឲ្យប៉ុស្តិ៍នគរបាលរដ្ឋបាលទួលសង្កែ តែម្តង ។

-តាមអំណានរបាយការណ៍សំយោគលេខ ០៤៧/១៧ រ.ប.ក ចុះថ្ងៃទី ២៥-០១-២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា: ជនសង្ស័យឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៩ ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ រំលោភលើទំនុកចិត្ត (យកសាប៊ូទៅលក់មិនឱ្យប្រាក់ក្រុមហ៊ុនចំនួន៣.១២៧,៧៥$(បីពាន់មួយរយម្ភៃប្រាំពីរដុល្លារអាមេរិក ក្បៀសចិតសិបប្រាំសេន) របស់តំណាងក្រុមហ៊ុនឈ្មោះ [redacted] ភេទ ស្រី អាយុ ៤៧ ឆ្នាំ កាលពី ថ្ងៃទី២៦.១២.២០១៦ វេលាម៉ោង ០៨:០០នាទី នៅចំណុចក្រុមហ៊ុនសាប៊ូប៊ីឌីស៊ីលីមីត ផ្លូវបេតុង ក្រុមទី១៤ ភូមិទួលថ្លាន់ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រាកដមែន ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ឆ្លងតាមការសួរដេញដោលពេលសវនាការនេះ ឃើញថាជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពនូវអំពើដែលខ្លួនប្រព្រឹត្ត ដែលមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងចម្លើយដើមបណ្តឹង និងចម្លើយសាក្សី តំណាងអយ្យការ យល់ឃើញថាជនជាប់ចោទឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៩ ឆ្នាំ ជាតិ ខ្មែរ ពិតជាបានប្រព្រឹត្តអំពើ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនសាប៊ូប៊ីឌីស៊ីលីមីត ផ្លូវបេតុង ក្រុមទី១៤ ភូមិទួលថ្លាន់ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦-១២-២០១៦ ប្រាកដមែន ។ តំណាងអយ្យការសូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ១១៨១ អ.យ.ប ចុះថ្ងៃទី២៤-០៤-២០១៧ ទុកជាបានការដដែល និងសូមតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ណូមពរ សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង ។



Scanned by CamScanner

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានពិនិត្យ និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងរាជធានីភ្នំពេញ**

**សំអាងហេតុ**

១.តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦១២ "ស" ដ.ជ ចុះថ្ងៃទី ០២-០៥-២០១៧ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ បានចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៩ ឆ្នាំ ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនសាប៊ូប៊ីឌីស៊ីលីមីត ផ្លូវបេតុង ក្រុមទី១៤ ភូមិទួលថ្នាន់ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦-១២-២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ៣៩១ , ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២.ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលនីតិវិធីប្រហាក់ប្រហែលគ្នាថា: ខ្លួនជាបុគ្គលិករបស់ក្រុមហ៊ុនប៊ីឌី ស៊ីលីមីត ផ្នែកចែកចាយសាប៊ូ ។ នៅថ្ងៃទី២៤-១២-២០១៦ វេលាម៉ោង ០៨:០០នាទី ខ្លួនយកសាប៊ូទៅបោះឲ្យម៉ូយនៅតាមផ្សារ ដោយគិតជាតម្លៃប្រាក់សរុបមានចំនួន ៣.១២៧,៧៥$ (បីពាន់មួយរយម្ភៃប្រាំពីរដុល្លាអាមេរិក ក្បៀសចិតសិបប្រាំសេន) ហើយខ្លួនមិនបានប្រគល់ប្រាក់ខាងលើឲ្យក្រុមនោះទេ ដោយយកប្រាក់ទាំងអស់ទៅសងបំណុលរបស់ប្រពន្ធខ្លួនដែលជំពាក់គេ។លុះដល់ថ្ងៃទី២៤-០១-២០១៧ វេលាម៉ោង០៧:៣០នាទី រូបខ្លួនបានចូលមកក្រុមហ៊ុន ត្រូវបានប្រធានរដ្ឋបាលឈ្មោះ [redacted] ហៅមកទូទាត់ប្រាក់ខាងលើឲ្យក្រុមហ៊ុន ហើយរូបខ្លួនបាននិយាយទៅកាន់ប្រធានរដ្ឋបាលថាប្រាក់ចំនួន៣.១២៧,៧៥ $ (បីពាន់មួយរយម្ភៃប្រាំពីរដុល្លាអាមេរិក ក្បៀសចិតសិបប្រាំសេន) រូបខ្លួនបានយកទៅសងបំណុលគេអស់ហើយ ភ្លាមៗនោះក៏ត្រូវប្រធានរដ្ឋបាលធ្វើការឃាត់រូបខ្លួនប្រគល់ឲ្យប៉ុស្តិ៍នគរបាលរដ្ឋបាលទួលសង្កែតែម្តង ។

៣.មេធាវីតំណាងអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា: ខ្លួនរក្សាការទាមទារដូចនៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់កូនក្តីខ្លួនទុកជាបានការដដែល ។ ចំពោះរឿងដែលឈ្មោះ [redacted] បានយកប្រាក់របស់ក្រុមហ៊ុនកូនក្តីខ្លួននោះ គឺបានកើតឡើងតាំងពីឆ្នាំ ២០១៥ រហូតមកដល់ខែមករា ដើមឆ្នាំ២០១៧នេះ ទើបកូនក្តីខ្លួនបានដាក់ពាក្យបណ្តឹងប្តឹងឈ្មោះ [redacted] ដោយមូលហេតុឈ្មោះនេះបានយកប្រាក់របស់ក្រុមហ៊ុនកូនក្តីខ្លួនជាច្រើនដងមកហើយ ទើបតែដើមឆ្នាំ២០១៧នេះ កូនក្តីខ្លួនបានសម្រេចដាក់ពាក្យបណ្តឹងសមត្ថកិច្ច និងរហូតមកដល់តុលាការតែម្តង។ ខ្លួនសូមបញ្ជាក់ថាប្រាក់ដែលឈ្មោះ [redacted] បានយកនោះមានចំនួន ៥.០៦១,៨៥ $ (ប្រាំពាន់សូន្យរយហុកសិបមួយដុល្លារអាមេរិក ក្បៀសប៉ែតសិបប្រាំសេន) គិតត្រឹមថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ហើយខាងកូនក្តីខ្លួនក៏បានកំពុងតែស្រាវជ្រាវបន្ថែមទៀតអំពីចំនួនទឹកប្រាក់ដែលឈ្មោះ [redacted] បានយកថាមានចំនួនសរុបប៉ុន្មាន ដោយសារថាការប្រព្រឹត្តរបស់ឈ្មោះ [redacted] បានប្រព្រឹត្តជាយូរមកហើយ ។

៤.តាមអំណានកំណត់ហេតុបណ្តឹង ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] នៅចំពោះមុខប៉ុស្តិ៍នគរបាលរដ្ឋបាលទួលសង្កែ បញ្ជាក់ថា: ឈ្មោះ [redacted] ភេទ ប្រុស បានចូលបំពេញការងារនៅក្រុមហ៊ុន BDC រយៈពេលពីរឆ្នាំហើយ នៅផ្នែកលក់សាប៊ូ ។ ប្រធានក្រុមហ៊ុនបានប្រគល់ឱ្យឈ្មោះ [redacted]



Scanned by CamScanner

[redacted]អ្នកដើរយកប្រាក់នៅទីផ្សារ ។ លុះនៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៧ វេលាម៉ោង ០៨៖០០ព្រឹក ខ្លួន([redacted]នៅផ្នែករដ្ឋបាលបានត្រួតពិនិត្យបុងប្រាក់បាត់ប្រាក់ចំនួន ៣.១២៧,៧៥$ (បីពាន់មួយរយម្ភៃប្រាំពីរដុល្លារអាមេរិក ក្បៀសចិតសិបប្រាំសេន) ដែលឈ្មោះ[redacted]ិនទាន់បានប្រគល់ឱ្យក្រុមហ៊ុនវិញទេ ហើយខ្លួនបានខំដើរទៅសួរគ្រប់ទីផ្សារ អាជីវករ ដែលបានទទួលយកសាប៊ូទៅលក់បន្ត ពួកគាត់បានប្រាប់ថាប្រគល់ប្រាក់ឱ្យឈ្មោះ[redacted]អ្នកយកប្រាក់ជារៀងរាល់លើកអស់ហើយ ។

៥.តាមអំណានចម្លើយរបស់សាក្សីឈ្មោះ[redacted]បានឆ្លើយនៅសមត្ថកិច្ច និងនៅចៅក្រមស៊ើបសួរ ប្រហាក់ប្រហែលគ្នាថា: នៅថ្ងៃទី២៤-០១-២០១៧ វេលាម៉ោង០៧:៣០នាទី រូបខ្លួនបានទៅកន្លែងធ្វើការក្នុងក្រុមហ៊ុនលក់សាប៊ូប៊ីឌីស៊ីលីមីត ស្រាប់តែឃើញប្រធានរដ្ឋបាលឈ្មោះ[redacted]ហៅឈ្មោះ[redacted] អ្នកលក់សាប៊ូនៅតាមទីផ្សារឲ្យមកទូទាត់ប្រាក់របស់ក្រុមហ៊ុន ក្រោយមកស្រាប់តែប្រធានរដ្ឋបាលបានហៅរូបខ្លួនឲ្យនាំឈ្មោះ[redacted]មកប្រគល់ឲ្យប៉ុស្តិ៍នគរបាលរដ្ឋបាលទួលសង្កែ តែម្តង ។

៦.តាមរបាយការណ៍សំយោគលេខ ០៤៧ / ១៧ រ.ប.ក ចុះថ្ងៃទី ២៥-០១-២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា: ជនសង្ស័យឈ្មោះ[redacted]ភេទ ប្រុស អាយុ ២៩ ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ រំលោភលើទំនុកចិត្ត (យកសាប៊ូទៅលក់មិនឱ្យប្រាក់ក្រុមហ៊ុនចំនួន ៣.១២៧,៧៥$) របស់តំណាងក្រុមហ៊ុនឈ្មោះ[redacted] ស្រី អាយុ ៤៧ ឆ្នាំ កាលពីថ្ងៃទី២៦.១២.២០១៦ វេលាម៉ោង ០៨៖០០នាទី នៅចំណុចក្រុមហ៊ុន សាប៊ូប៊ីឌីស៊ីលីមីត ផ្លូវបេតុង ក្រុមទី១៤ ភូមិទួលថ្នាន់ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រាកដមែន ។

៧.តាមចម្លើយរបស់ជនជាប់ចោទ , ចម្លើយរបស់ដើមបណ្តឹង សាក្សី និង របាយការណ៍សំយោគលេខ ០៤៧/១៧ រ.ប.ក ចុះថ្ងៃទី២៥-០១-២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ មានលក្ខណៈស៊ីសង្វាក់គ្នាបញ្ជាក់បានថា៖ កាលពីថ្ងៃទី ២៦-១២-២០១៦ ពិតជាមានអំពើរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនសាប៊ូប៊ីឌីស៊ីលីមីត ផ្លូវបេតុង ក្រុមទី១៤ ភូមិទួលថ្នាន់ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បង្កឡើងដោយឈ្មោះ[redacted] ភេទ ប្រុស អាយុ ២៩ ឆ្នាំ ប្រាកដមែន ។

៨.ជនជាប់ចោទឈ្មោះ[redacted]ជានីតិជន មានស្មារតីដឹងខុសត្រូវ ដឹងច្បាស់នូវរាល់ហេតុការណ៍ដែលខ្លួនបានប្រព្រឹត្ត ហេតុនេះត្រូវទទួលខុសត្រូវនូវអំពើល្មើសរបស់ខ្លួនចំពោះមុខច្បាប់ ។

៩.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted]ភេទ ប្រុស អាយុ ២៩ ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនសាប៊ូប៊ីឌីស៊ីលីមីត ផ្លូវបេតុង ក្រុមទី១៤ ភូមិទួលថ្នាន់ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦-១២-២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

១០.អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈសណ្តាប់ធ្នាប់ក្នុងសង្គម មិនតែប៉ុណ្ណោះធ្វើឱ្យបាត់បង់ និងខូចខាតផលប្រយោជន៍របស់អ្នកដទៃ ។

១១.មេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី សំណូមពរសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងទៅទាមទារប្រាក់ ចំនួន ៥.០៦១,៨៥ $ (ប្រាំពាន់សូន្យរយហុកសិបមួយដុល្លារអាមេរិក ក្បៀសប៉ែតសិបប្រាំសេន) មកវិញ ។

១២.តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់របស់ខ្លួននៅដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

១៣.ជនជាប់ចោទបានសំណូមពរ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ។



Scanned by CamScanner

## ហេតុដូច្នេះ សាលាដំបូងរាជធានីភ្នំពេញ

**វិនិច្ឆ័យសេចក្តី**

១/.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៩ ឆ្នាំ ជាតិ ខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២.០០០.០០០ ៛ (ពីរលាន)រៀល ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនសាប៊ូប៊ីជីស៊ីលីមីត ផ្លូវបេតុង ក្រុមទី១៤ ភូមិទួលថ្នាន់ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦-១២-២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៩១ , ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២/.បង្គាប់ឱ្យឈ្មោះ [redacted] សងប្រាក់ចំនួន ៥.០៦១,៨៥ $ (ប្រាំពាន់សូន្យរយហុកសិបមួយដុល្លារអាមេរិក ប៉ែតសិបប្រាំសេន) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីវិញ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ០៤-០៧-២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៨-០៧-២០១៧ ចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និង ត្រា : | ហត្ថលេខា និង ត្រា : |
| [redacted] | [redacted] |

---

- បានចម្លងត្រឹមត្រូវតាមច្បាប់ដើម -

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧

| | |
|---|---|
| បានឃើញ | **ក្រឡាបញ្ជី** |
| **ចៅក្រមជំនុំជម្រះ** | |
| [redacted] | [redacted] |



Scanned by CamScanner